# របាយការណ៍អតិផរណាប្រចាំខែកញ្ញា ឆ្នាំ២០១១

## សម្រាប់កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី ២៣

ភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១

## II. ស្ថានភាពសេដ្ឋកិច្ចនិងធនាគារនៅកម្ពុជា

### ក/. កំណើនសេដ្ឋកិច្ច

នៅឆ្នាំ២០១១នេះ បើតាមការព្យាករណ៍ដោយប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលកាលពីដើមឆ្នាំ បានឱ្យដឹងថា កំណើនសេដ្ឋកិច្ចកម្ពុជានឹងអាចឡើងដល់ជិត ៧% ប៉ុន្តែដោយសារបញ្ហាប្រឈមនៃសេដ្ឋកិច្ចតំបន់និងពិភពលោក និងផលប៉ះពាល់ពីគ្រោះទឹកជំនន់ធ្ងន់ធ្ងរ នាពេលបច្ចុប្បន្ន ត្រូវបានគណនាស្ថិតនៅក្នុងរង្វង់ ៦%វិញ ខណៈដែលមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា កម្ពុជានឹងទទួលបានកំណើនសេដ្ឋកិច្ច ៦,៧%[1] នៅឆ្នាំ ២០១១នេះ ។

វិស័យសំខាន់ៗដែលរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ មានវិស័យឧស្សាហកម្មនឹងកើនឡើងប្រមាណ ៨,៥% ធៀបនឹង ១៣,៦% ក្នុងឆ្នាំ២០១០ ដែលក្នុងនោះផ្នែកឧស្សាហកម្មកាត់ដេរនឹងមានកំណើន ១១,២% ធៀបនឹង ១០,៤% ក្នុងឆ្នាំ២០១០, វិស័យកសិកម្មនឹងមានកំណើនប្រមាណ ៣,៦% ធៀបនឹង ៤% ក្នុងឆ្នាំ២០១០ ហើយវិស័យសេវាកម្មនឹងមានកំណើន ៦,៣% ធៀបនឹង ៣,៣% ក្នុងឆ្នាំ២០១០ ដែលក្នុងនោះផ្នែកសេវាកម្មទេសចរណ៍ នឹងមានកំណើនប្រហាក់ប្រហែលនឹងឆ្នាំ២០១០ គឺ ៦,៧% ។ អត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពធៀបនឹងប្រាក់ដុល្លារ ។ អតិផរណាជាមធ្យមប្រចាំឆ្នាំត្រូវបានរក្សាក្នុងរង្វង់ ៥,៥% ។ ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងដល់ប្រមាណ ៣ពាន់លានដុល្លារ ត្រឹមខែកញ្ញា ដែលអាចធានាការនាំចូលបានជាង ៤ខែ ។

### ខ/- ស្ថានភាពអត្រាប្តូរប្រាក់




រូបភាព ៧ : ស្ថានភាពប្រាក់រៀលនិងរូបិយប័ណ្ណបរទេស

នៅក្នុងរយៈពេល៩ខែឆ្នាំ២០១១នេះ ប្រាក់រៀលបានឡើងថ្លៃ ៣,៧% ធៀបនឹងប្រាក់ដុល្លារអាមេរិកក្នុងគ្រាដូចគ្នានៅឆ្នាំ ២០១០ ។ ប៉ុន្តែនៅខែកញ្ញាឆ្នាំនេះ ប្រាក់រៀលបានឡើងថ្លៃចំនួន ៣,៨% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំមុន ដោយសារការកើនឡើងនៃតម្រូវការប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ច ។ កំណើននៃតម្រូវការនេះអាចឆ្លុះបញ្ចាំងតាមរយៈកំណើនរូបិយវត្ថុប្រចាំឆ្នាំក្នុងចរាចរណ៍ចំនួនជាង ២១% នាខែកញ្ញាឆ្នាំ២០១១នេះ បន្ទាប់ពីបានជំរុញការប្រើប្រាស់ប្រាក់រៀល និងការថយចុះនៃតម្លៃប្រាក់ដុល្លារនៅលើទីផ្សារអន្តរជាតិ ។ បើធៀបជាមួយនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួន ប្រាក់រៀលបានឡើងថ្លៃ ៦,៥% ធៀបនឹងប្រាក់វ៉ុនកូរ៉េ ៥,៨% ធៀបនឹងប្រាក់បាតថៃ ១០,១% ធៀបនឹងប្រាក់ដុងវៀតណាម ៦,៥% ធៀបនឹងប្រាក់រីងហ្គិត ១,៩% ធៀបនឹងប្រាក់ដុល្លារសិង្ហបុរី ៣,៨% ធៀបនឹងប្រាក់ដុល្លារហុងកុង ៣,៧%ធៀបនឹងប្រាក់អឺរ៉ូ ប៉ុន្តែបានធ្លាក់ថ្លៃ ០,៨% ធៀបនឹងប្រាក់យ៉ន់ចិន ៥,៤% ធៀបនឹងប្រាក់យ៉េនជប៉ុន នៅក្នុងខែកញ្ញាឆ្នាំ២០១១ ធៀបនឹងខែដូចគ្នាឆ្នាំ២០១០ ។

### គ/- ចលនាអត្រាការប្រាក់

[1] ការវាយតម្លៃរបស់ IMF កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១

គិតត្រឹមរយៈពេល៩ខែនៅឆ្នាំនេះ ទោះបីប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុពិភពលោក កំពុងប្រឈមនឹងការលំបាក ក៏វិស័យធនាគារនៅកម្ពុជានៅតែបង្ហាញពីសុវត្ថិភាពតាមរយៈការបន្តផ្តល់ឥណទាននិងការបញ្ចុះអត្រាការប្រាក់ឥណទានជាបន្តបន្ទាប់ ។ បើពិនិត្យតាមអត្រាការប្រាក់ថ្លឹងរយៈពេល៦ខែឃើញថា គ្រឹះស្ថានធនាគារនៅកម្ពុជាបានកាត់បន្ថយអត្រាការប្រាក់ឥណទានជាប្រាក់ដុល្លារពីប្រមាណ ១៩% នៅដំណាច់ឆ្នាំ២០១០ មកត្រឹមជាង ១៥% នៅខែកញ្ញាឆ្នាំ២០១១ និងជាប្រាក់រៀលពីជិត ២២% មកជិត ១៥% ។ រីឯអត្រាការប្រាក់បញ្ញើជាដុល្លារបានថយចុះបន្តិចបន្តួចមកត្រឹម ៣,៤% និងប្រាក់រៀល ៥,៤% នៅក្នុងខែកញ្ញាឆ្នាំ២០១១នេះ ។

រូបភាព ៨ : អត្រាការប្រាក់បញ្ញើនិងឥណទាន




### ឃ/- ស្ថានភាពរូបិយវត្ថុ

ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ បរិមាណឥណទានចំពោះវិស័យឯកជននិងរូបិយវត្ថុទូទៅបានកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

**- អត្រាកំណើនរូបិយវត្ថុទូទៅ (M2)** មានអត្រាកំណើនឆ្នាំលើឆ្នាំ ២១% ប៉ុន្តែទាបជាងកំណើនក្នុងរយៈពេលដូចគ្នានៅឆ្នាំ២០១០ ដែលមានកំណើនដល់ទៅ ២៧% ។ នៅក្នុងកំណើនរូបិយវត្ថុទូទៅ ២១% នេះ មានចំណែកប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ១៦% និងរូបិយវត្ថុក្នុងចរាចរណ៍ប្រមាណ ៥% ។ ម្យ៉ាងទៀត ក្នុងចំណោមកំណើនរូបិយវត្ថុទូទៅ ២១% នេះ បានរួមចំណែកដោយទ្រព្យសកម្មបរទេសសុទ្ធ ៥% និងទ្រព្យសកម្មក្នុងស្រុកសុទ្ធ ១៦% ។

**- ប្រាក់បញ្ញើអតិថិជនក្នុងប្រព័ន្ធធនាគារ** មានអត្រាកំណើនឆ្នាំលើឆ្នាំស្មើនឹង ២០% នៅខែកញ្ញាឆ្នាំ២០១១នេះ ប៉ុន្តែទាបជាងកំណើននាខែកន្លងទៅដែលកើនដល់ ២២% និងទាបជាងកំណើននៅគ្រាដូចគ្នាឆ្នាំ២០១០ ដែលមានរហូតដល់ ៣០% ។

**- ឥណទានចំពោះវិស័យឯកជន** មានកំណើនឆ្នាំលើឆ្នាំស្មើនឹង ៣១% នៅខែកញ្ញាឆ្នាំ២០១១នេះ ធៀបគ្រាដូចគ្នាឆ្នាំ២០១០ កំណើន នេះធ្លាប់មានត្រឹមតែ ២៣% ។

រូបភាព ៩ : ឥណទានឱ្យទៅវិស័យឯកជន, ប្រាក់បញ្ញើ និងរូបិយវត្ថុទូទៅ




រូបភាព ១០ : រូបិយវត្ថុទូទៅ, ទ្រព្យសកម្មបរទេសសុទ្ធ និង COB




## III- ស្ថានភាពអតិផរណារបស់កម្ពុជានាខែកញ្ញា ឆ្នាំ២០១១

### ក/- ស្ថានភាពអតិផរណា

#### ១- អតិផរណាប្រចាំខែ

អតិផរណាខែលើខែក្នុងខែនេះបានកើនដល់ ១% បន្ទាប់ពីបានថយចុះបីខែជាប់គ្នាពី ១,៤% នៅខែឧសភាឆ្នាំ២០១១ មក ។ អតិផរណាខែកញ្ញាឆ្នាំ២០១១នេះ មានកម្រិតខ្ពស់ជាងខែដូចគ្នាកាលពី២ឆ្នាំមុនផងដែរ ។ ក្នុង

ចំណោមថ្លៃទំនិញទាំង១២ក្រុម មាន១១ក្រុមបានឡើងថ្លៃ និង១ក្រុមបានចុះថ្លៃ ។ ក្រុមទំនិញ ១១ ក្រុមដែលឡើងថ្លៃ មានក្រុមទំនិញនិងសេវាផ្សេងៗចំនួន ១,៨% ក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ១,៥% ក្រុមសំលៀកបំពាក់និងស្បែកជើង ១,៣% ក្រុមដឹកជញ្ជូន ១% ក្រុមគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំផ្ទះជាប្រចាំ ០,៨% ក្រុមការសិក្សា ០,៨% ក្រុមការកម្សាន្តនិងវប្បធម៌ ០,៥% ក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ ០,២% ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ន/និងឥន្ទនៈដទៃទៀត ០,១% ក្រុមភោជនីយដ្ឋាន ០,១% និងក្រុមគមនាគមន៍ ០,០១% ។ ចំណែកឯក្រុមទំនិញ១ក្រុមដែលចុះថ្លៃគឺក្រុមសុខាភិបាលថយចុះចំនួន ០,១% ។



រូបភាព ១១ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (△% ខែលើខែ)



រូបភាព ១២ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់, តាមក្រុម (△% ខែលើខែ)

## ២- អតិផរណាប្រចាំឆ្នាំ

អត្រាអតិផរណារួមមធ្យមឆ្នាំលើឆ្នាំក្នុងរយៈពេល ៩ខែដើមឆ្នាំ២០១១នេះ ស្មើនឹង ៥,៥%[2] ខ្ពស់ជាងឆ្នាំ ២០១០ ដែលមានកម្រិតជិត ៥% ។ រីឯអត្រាអតិផរណារួមឆ្នាំលើឆ្នាំនៅខែកញ្ញានេះស្មើនឹង ៦,៧% ខ្ពស់ជាងខែដូចគ្នាឆ្នាំ២០១០ ដែលមានត្រឹម ១,៩% ប៉ុណ្ណោះ ។ ក្នុងខែកញ្ញានេះ អតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃក្រុមម្ហូបអាហារស្មើនឹង ៥,៣% ខណៈដែលអតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ទនៈ ដែលបញ្ចូលទាំងថ្លៃសេវាក្រុមដឹកជញ្ជូនផងនោះ ស្មើនឹង ៦,៤% ។



រូបភាព ១៣ : អតិផរណាតាមក្រុម (បម្រែបម្រួលជា% ឆ្នាំលើឆ្នាំ)

គួរកត់សម្គាល់ថា ក្នុងចំណោមមេគុណ១០០ក្នុងការគណនាអតិផរណានេះ ក្រុមម្ហូបអាហារនិងភេសជ្ជៈពុំមានជាតិស្រវឹងបានស្រូបយកមេគុណអស់ ៤៤,៧៨% ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ននិងឥន្ទនៈដទៃទៀត ១៧,០៧% ក្រុមដឹកជញ្ជូន ១២,២៣% និងក្រុមភោជនីយដ្ឋាន ៥,៨៦% ។ ដូច្នេះ នៅពេលក្រុមទាំងនេះមានការប្រែប្រួលនឹងធ្វើឱ្យថ្លៃទំនិញនិងសេវាប្រែប្រួលភ្លាមៗដែរ ។ នៅខែកញ្ញា ក្រុមម្ហូបអាហារនិងភេសជ្ជៈពុំមានជាតិស្រវឹង បានកើនឡើងចំនួន ៨,១% ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ននិងឥន្ទនៈដទៃទៀត ៥,៣% ក្រុមដឹកជញ្ជូន ៨,៩% និងក្រុមភោជនីយដ្ឋាន៧,៣% ធៀបនឹងគ្រាដូចគ្នានាឆ្នាំមុន ។

| Contribution (YoY %) | Jul-11 | Aug-11 | Sep-11 |
|---|---|---|---|
| All Items | 7.1 | 6.4 | 6.7 |
| Food & N A B | 4.0 | 3.4 | 3.6 |
| Transportation | 1.1 | 1.0 | 1.1 |
| Housing W E. | 0.7 | 0.7 | 0.9 |
| Restaurants | 0.6 | 0.5 | 0.4 |
| Miscellaneous Goods&S. | 0.2 | 0.2 | 0.3 |
| Others | 0.2 | 0.1 | 0.1 |

[2] រាជរដ្ឋាភិបាលបានប្តេជ្ញាគ្រប់គ្រងអត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៥,៥% (សុន្ទរកថារបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១)

ជារួម អតិផរណារួមប្រចាំឆ្នាំនៅខែកញ្ញាឆ្នាំ២០១១ ស្មើនឹង ៦,៧% ដោយសារកំណើនថ្លៃ ៖ ១/- ក្រុមម្ហូបអាហារនិងភេសជ្ជៈពុំមានជាតិស្រវឹង ៣,៦% ២/-ក្រុមដឹកជញ្ជូន ១,១% ៣/- ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ន និងឥន្ធនៈដទៃទៀត ០,៩% ៤/- ក្រុមភោជនីយដ្ឋាន ០,៤% ៥/- ក្រុមទំនិញនិងសេវាផ្សេងៗ ០,៣% និង ៦/- ក្រុម ផ្សេងទៀតត្រឹម ០,១% ។

### ខ/- មូលហេតុដែលមានឥទ្ធិពលលើអតិផរណាក្នុងស្រុក

### ១- កត្តាថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ

រូបភាព ១៤ : សន្ទស្សន៍ថ្លៃម្ហូបអាហារពិភពលោក (FAO)




សម្ពាធអត្រាអតិផរណាក្នុងស្រុកបណ្តាលមកពីឥទ្ធិពលនៃកត្តាខាងក្រៅច្រើនជាង ព្រោះថានៅខែកញ្ញាឆ្នាំ២០១១នេះ កំណើនថ្លៃម្ហូបអាហារពិភពលោកឆ្នាំលើឆ្នាំបានកើនឡើងរហូតដល់ ១៩% នាពេលបច្ចុប្បន្ន ប៉ុន្តែកំណើនខែលើខែបានថយចុះប្រមាណ ០,២% ។

ការកើនឡើងនៃថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ ស្មើនឹង ០,៧ ដុល្លារអាមេរិកក្នុង១លីត្រ ពោលគឺបានកើនឡើង ៣,៥% ធៀបនឹងខែដូចគ្នានៅឆ្នាំកន្លងមក ខណៈថ្លៃប្រេងឥន្ធនៈ ក្នុងស្រុកស្មើនឹង ១,៣ ដុល្លារអាមេរិក ក្នុង១លីត្រ ពោលគឺ បានកើនឡើង ១,៩% ធៀបនឹងខែមុន និងបានកើនឡើង ប្រមាណ២០% ធៀបនឹងខែដូចគ្នានាឆ្នាំកន្លងទៅ ។

រូបភាព ១៥ : ថ្លៃប្រេងឥន្ធនៈក្នុងស្រុកនិងថ្លៃប្រេងឆៅពិភពលោក




គួរកត់សម្គាល់ថាទោះបីជាថ្លៃប្រេងឆៅអន្តរជាតិបានថយចុះ ប៉ុន្តែថ្លៃប្រេងឥន្ធនៈនៅកម្ពុជាមិនទាន់ថយចុះហើយនៅមានតម្លៃខ្ពស់ដដែល ។ ទាំងនេះជាកាតាលីករក្នុងការជំរុញថ្លៃផលិតកម្ម ថ្លៃទំនិញនិងសេវាបានកើនឡើងនៅលើទីផ្សារនៅក្នុងស្រុកនាពេលបច្ចុប្បន្ននេះ ។

ដោយកម្ពុជាជាប្រទេសដុល្លាររូបនីយកម្ម ការធ្លាក់ថ្លៃនៃប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណប្រទេសជាដៃគូពាណិជ្ជកម្ម បានធ្វើឱ្យបាត់បង់នូវអំណាចទិញរបស់ប្រាក់ដុល្លារ និងរួមចំណែកធ្វើឱ្យតម្លៃទំនិញនាំចូលកើនឡើងផងដែរនៅពេលទូទាត់ជាដុល្លារ ។

សរុបមក កត្តាដែលនាំឱ្យមានសម្ពាធអតិផរណានៅកម្ពុជា គឺមានឫសគល់មកពីកត្តាខាងក្រៅច្រើនជាងកត្តារូបិយវត្ថុនិងកត្តាក្នុងស្រុក ដែលមានលក្ខណៈតាមរដូវកាលរយៈពេលខ្លីនិងបណ្តោះអាសន្នប៉ុណ្ណោះ ។

### ២- កត្តាអតិផរណានាំចូលពីប្រទេសជិតខាងជាដៃគូពាណិជ្ជកម្ម

ប្រទេសកម្ពុជាជាប្រទេសតូច សេដ្ឋកិច្ចមានលក្ខណៈបើកចំហ ហើយបានពឹងផ្អែកទៅលើទំនិញនាំចូលពីប្រទេសជាដៃគូពាណិជ្ជកម្មដើម្បីបំពេញតម្រូវការក្នុងស្រុក ។ នៅក្នុងខែកញ្ញាឆ្នាំនេះ ប្រទេសចិនបាននាំចូលទំនិញមកកម្ពុជាចំនួន ១៧,៤% ប្រទេសថៃ ១០,២% ហុងកុង ៨,១% និងប្រទេសវៀតណាម ៧,២% នៃការនាំចូលសរុប ខណៈដែលប្រទេសចិនមានអតិផរណាឆ្នាំលើឆ្នាំ ៦,១% ប្រទេសថៃ ៤% ហុងកុង ៥,៨% ប្រទេសវៀតណាម

២២,៤% ។ ការនាំចូលទំនិញពីប្រទេសដៃគូពាណិជ្ជកម្មដែលមានអតិផរណាខ្ពស់ស្រាប់ ជាមូលហេតុសំខាន់ដែលធ្វើឱ្យសេដ្ឋកិច្ចមានសម្ពាធអតិផរណានៅក្នុងស្រុកគួរឱ្យព្រួយបារម្ភផងដែរ ។